ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៣៣៩
ចុះថ្ងៃទី០៥-១២-២០១៦

សាលដីកា
លេខ: ៥០ "ក្រ III ន"
ចុះថ្ងៃទី១៦-៨-២០១៧

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រឹត្យលេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-៧-២០១៤ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី៣១-៧-២០១៧ ដោយមានសមាសភាព ដូចតទៅ:

<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>

លោកស្រី [redacted] ជាប្រធាន

ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted] ជាព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជីសវនាការ</u>

លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងក្តីព្រហ្មទណ្ឌលេខ: ១៣៣៩ ចុះថ្ងៃទី០៥-១២-២០១៦ ដែលមាន:

-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ១៩៩២ ជាតិខ្មែរ មុខរបរស៊ីឈ្នួលធ្វើម្ហូបការ កំរិតវប្បធម៌ថ្នាក់ទី១២ ទីកន្លែងកំណើតភូមិតាងោ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅភូមិតាងោ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ប្តឹងឧទ្ធរណ៍)

<u>ជាប់ចោទពីបទ:</u> ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស(ដោយសារការប្រើអំពើហិង្សា) ប្រព្រឹត្តនៅ ចំណុចមុខផ្ទះលេខ៩០ ផ្លូវលេខ៦៤៤ ស្ថិតនៅភូមិដើមអំពិល សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ មាត្រា ៣៥៣ មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

មានលោក [redacted] ងលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។



Scanned by CamScanner

-ជនរងគ្រោះឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ១៩៩៨ ជាតិខ្មែរ មុខរបរបុគ្គលិកផ្សារ ទីលំនៅបច្ចុប្បន្នស្នាក់ផ្ទះជួលលេខ១១៧ ផ្លូវលំ ភូមិតាងោ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៦ វេលាម៉ោង២រំលងអធ្រាត្រឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស និងឈ្មោះ [redacted] ជិះម៉ូតូមួយគ្រឿងម៉ាក SUZUKL NEX មកដល់ចំណុចមុខផ្ទះលេខ៩០ ផ្លូវ៦៤៤ ស្ថិតនៅភូមិដើមអំពិល សង្កាត់ច្បារអំពៅ១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ក៏បានជួបនឹងឈ្មោះ [redacted] ភេទស្រី និងបងស្រីជីដូនមួយកំពុងជិះម៉ូតូ។ ពេលនោះឈ្មោះ [redacted] ជិះម៉ូតូកៀរម៉ូតូឈ្មោះ [redacted] បណ្ដាលឱ្យដួលម៉ូតូ ហើយឈ្មោះ [redacted] បានចុះទៅឆក់កាបូបស្ពាយពីឈ្មោះ [redacted] តែមិនបានសម្រេចហើយក៏មានរថយន្តមួយគ្រឿងមកដល់បានបុកម៉ូតូឈ្មោះ [redacted] ពីក្រោយបណ្ដាលឱ្យដួលរួច ឈ្មោះ [redacted] និងឈ្មោះ [redacted] រត់ខ្លួនបាត់។ រហូតដល់ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ ទើបសមត្ថកិច្ចចាប់ខ្លួនបានឈ្មោះ [redacted]។

-បានឃើញ: សាលក្រមព្រហ្មទណ្ឌលេខព្រហ្មទណ្ឌលេខ: ៤៧១ ក្រ.១ "ន" ចុះថ្ងៃទី២៧-១០-២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចខាងក្រោម៖

១.ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ហៅ ទុំ ភេទប្រុស កើតឆ្នាំ១៩៩២ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៤(បួន)ឆ្នាំ ពីបទ: ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស(ដោយសារការប្រព្រឹត្តអំពើហិង្សា) ប្រព្រឹត្តនៅ ចំណុចមុខផ្ទះលេខ៩០ ផ្លូវលេខ៦៤៤ ស្ថិតនៅភូមិដើមអំពិល សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ មាត្រា៣៥៣ មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២.វត្ថុតាងដែលចាប់យកមានម៉ូតូមួយគ្រឿងម៉ាក SUZUKI NEX ពណ៌លឿងលាយស ពាក់ស្លាកលេខភ្នំពេញ 1DD-3527 មានលេខតួ និងលេខម៉ាស៊ីន 311421 (បែកស្លុបខាងក្រោយមិនប្រក្រតី) សម្រេចរឹបអូសជាសម្បត្តិរដ្ឋ តាមមាត្រា៦២ និង ៦៣ នៃក្រមព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] កំបាំងមុខជនរងគ្រោះឈ្មោះ [redacted] បើកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញ: ពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-១១-២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ សុំប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៧១ ក្រ.១ "ន" ចុះថ្ងៃទី២៧-១០-២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ: របាយការណ៍សំណុំរឿងព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ចុះថ្ងៃទី០៣-៣-២០១៧ ។

-បានឃើញ: សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ចុះថ្ងៃទី១៨-៥-២០១៧ ។

Scanned by CamScanner

## នាពេលជំនុំជម្រះ

-ជនជាប់ចោទឈ្មោះ [redacted] (វត្តមាន)

-លោកមេធាវី [redacted] និងលោក ហាក់ លីមហួរ (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍ដោយមូលហេតុថា តុលាការថ្នាក់ក្រោមដាក់ទោសខ្លួនធ្ងន់ពេក ស្នើសុំឱ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ព្រោះខ្លួនគ្មានចេតនាវាយទេ គឺប៉ះដៃប៉ុណ្ណោះ ។

### តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា

បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទធ្វើឡើងត្រឹមត្រូវតាមច្បាប់ ។ ជនជាប់ចោទបានសារភាពអស់ហើយ ព្យសនកម្មមិនខូចខាតធ្ងន់ធ្ងរពេកទេ តំណាងមហាអយ្យការមិនជំទាស់នឹងការស្នើសុំបន្ធូរបន្ថយទោសទេ គួរក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសដល់ជនជាប់ចោទតាមច្បាប់ ។

-លោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនបានសារភាពអស់ហើយថា ខ្លួនពិតជាបានប្រព្រឹត្តប្រាកដមែន ព្យសនកម្មតិចតួច ហើយកូនក្តីខ្លួនគ្មានចេតនាប្រព្រឹត្តទេ ។ ដូចនេះ សូមក្រុមប្រឹក្សាសម្រេចកែប្រែបទចោទពី លួចមានស្ថានទម្ងន់ទោស មកជាបទ លួច វិញ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវហើយ

## សាលាឧទ្ធរណ៍

## យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-១១-២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៤៧១ ក្រ១ "ន" ចុះថ្ងៃទី២៧-១០-២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងក្របខ័ណ្ឌច្បាប់ យោងតាមមាត្រា៣៧៣ មាត្រា ៣៧៥ មាត្រា ៣៧៦ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ទទួលជំនុំជម្រះសំណុំរឿងលេខ១៣៣៩ ចុះថ្ងៃទី០៥-១២-២០១៦ របស់សាលាឧទ្ធរណ៍បានជាសមត្ថកិច្ច។



Scanned by CamScanner

២-ក្រោយការសួរដេញដោល ក៏ដូចជាការពិនិត្យភស្តុតាងក្នុងសំណុំរឿងឃើញថាៈ កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៦ វេលាម៉ោង២រំលងអាធ្រាត្រ ជនជាប់ចោទឈ្មោះ [redacted]និងឈ្មោះ [redacted] បានជិះម៉ូតូមួយគ្រឿងម៉ាក SUZUKI NEX មកដល់ចំណុចមុខផ្ទះលេខ៩០ ផ្លូវ៦៤៤ ស្ថិតនៅភូមិដើមអំពិល សង្កាត់ច្បារអំពៅ១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ក៏បានជួបនឹងជនរងគ្រោះឈ្មោះ [redacted]រងស្រីជីដូនមួយកំពុងជិះម៉ូតូ ។ ពេលនោះជនជាប់ចោទឈ្មោះ [redacted] បានជិះម៉ូតូកៀរម៉ូតូជនរងគ្រោះ បណ្តាលឲ្យដួលម៉ូតូ ហើយឈ្មោះ [redacted] ចុះទៅឆក់កាបូបស្ពាយពីជនរងគ្រោះ តែមិនបានសម្រេច ហើយក៏មានរថយន្តមួយគ្រឿងមកដល់បានបុកម៉ូតូជនជាប់ចោទពីក្រោយ បណ្តាលឲ្យដួលរបួស ជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] បាត់ ។ ក្រោយមកទើបសមត្ថកិច្ចចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] បាននៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ ។

៣-សកម្មភាពរបស់ជនជាប់ចោទខាងលើ គឺជាទម្រង់មួយនៃអំពើ ដែលមានធាតុផ្សំនិងភស្តុតាងដាក់បន្ទុកលើជនជាប់ចោទពីបទ ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស(ដោយសារការប្រព្រឹត្តអំពើហិង្សា) ដែលច្បាប់បានចែងនិងតម្រូវឲ្យផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ដូចមានក្នុងសំអាងហេតុនៃសាលក្រមព្រហ្មទណ្ឌលេខ៤៧១ ក្រ១ "ន" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បានឯកភាព ។ ដូចនេះសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ពុំលើកយកសំអាងហេតុដដែលនោះមកបញ្ជាក់ជាថ្មីទៀតទេ។

៤-នាពេលសវនាការនៅសាលាឧទ្ធរណ៍ ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍ដោយមូលហេតុថា តុលាការថ្នាក់ក្រោមដាក់ទោសខ្លួនធ្ងន់ពេក ស្នើសុំឱ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ព្រោះខ្លួនគ្មានចេតនាវាយទេ ។

៥-តំណាងមហាអយ្យការបានសន្និដ្ឋានថា៖ បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់។ ជនជាប់ចោទបានសារភាពអស់ហើយ ព្យសនកម្មមិនខូចខាតធ្ងន់ធ្ងរពេកទេ តំណាងមហាអយ្យការមិនជំទាស់នឹងការស្នើសុំបន្ធូរបន្ថយទោសទេ គួរក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសដល់ជនជាប់ចោទតាមច្បាប់ ។

៦-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានសន្និដ្ឋានថា កូនក្តីខ្លួនបានសារភាពអស់ហើយ ថា ខ្លួនពិតជាបានប្រព្រឹត្តប្រាកដមែន ប៉ុន្តែព្យសនកម្មតិចតួច ហើយកូនក្តីខ្លួនគ្មានចេតនាប្រព្រឹត្តទេ ។ ដូចនេះ សូមក្រុមប្រឹក្សាសម្រេចកែប្រែបទចោទពី លួចមានស្ថានទម្ងន់ទោស មកជាបទ លួច វិញ ។ ការលើកឡើងនេះ ពុំមានមូលដ្ឋានផ្លូវច្បាប់ដើម្បីឱ្យសភាព្រហ្មទណ្ឌពិចារណាបានឡើយ ។

៧-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស(ដោយសារការប្រើអំពើហិង្សា) ប្រព្រឹត្តនៅ ចំណុចមុខផ្ទះលេខ៩០ ផ្លូវលេខ៦៤៤ ស្ថិតនៅភូមិដើមអំពិល សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ មាត្រា៣៥៣ មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

Scanned by CamScanner

៨-សាលក្រមព្រហ្មទណ្ឌលេខ៤៧១ ក្រ១ "ន" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្ដីមកនេះត្រឹមត្រូវតាមអង្គហេតុនឹងគតិច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-១១-២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៧១ ក្រ១ "ន" ចុះថ្ងៃទី២៧-១០-២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។

សាលដីកានេះបានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣១-០៧-២០១៧ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦-០៨-២០១៧ ។

ទុក្ខសិទ្ធិប្ដឹងឧទ្ធរណ៍តាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេ[redacted] | ហត្ថលេខា [redacted] | ហត្ថលេខ[redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ភ្នំពេញ, ថ្ងៃទី14 ខែ [illegible] ឆ្នាំ២០១៧

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

Scanned by CamScanner